ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# បច្ចេកទេសចិញ្ចឹមគោ
# ជាលក្ខណៈគ្រួសារ




**រៀបចំដោយ:**

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

សហការជាមួយ នាយកដ្ឋានផលិតកម្ម នាយកដ្ឋានផ្សព្វផ្សាយ

បច្ចេកទេស និងនីតិកម្ម នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ



ឧបត្ថម្ភការបោះពុម្ពដោយ: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឆ្នាំ២០១៩

## មាតិកា

ទំព័រ


I. **សេចក្តីផ្តើម** ........................................ ១

១. ជម្រក ឬរោងគោ ........................................ ២

២. ស្តុកចំណី និងទឹក ........................................ ៣

៣. ការជ្រើសរើសពូជគោ ........................................ ៣

៤. តម្រូវការសារធាតុចិញ្ចឹមសម្រាប់គោ ........................................ ៨

II. **ដំណាំចំណីសត្វសំខាន់ៗ** ........................................ ១១

១. ពពួកស្មៅ ........................................ ១១

២. ពពួកលេហ្គីម ........................................ ១១

៣. ឈ្មោះប្រភេទពូជដំណាំចំណីសត្វសំខាន់ៗ ដែលបានដាំនៅកម្ពុជា.១២

៤. ពពួកស្មៅ និងអត្ថប្រយោជន៍ ........................................ ១៧

៥. ពពួកលេហ្គីម និងអត្ថប្រយោជន៍ ........................................ ២០

៦. ប្រភេទដំណាំផ្សេងៗទៀត និងអត្ថប្រយោជន៍ ........................................ ២១

III. **បច្ចេកទេសកែច្នៃចំណីសត្វ** ........................................ ២២

១. ការធ្វើផ្អកស្មៅជាចំណីបំប៉នគោក្របី ........................................ ២២

២. ការធ្វើចំបើងផ្អាប់ជាចំណីគោ ........................................ ២៦

៣. ការកែច្នៃស្លឹកដំឡូងមី ........................................ ២៩

៤. ការធ្វើចំណីផ្សំតាមផ្ទះកសិករ សម្រាប់ជាចំណីបំប៉នគោ ........................................ ៣៣




# បច្ចេកទេសចិញ្ចឹមគោជាលក្ខណៈគ្រួសារ

## I. សេចក្តីផ្តើម

វិស័យកសិកម្មមានការរីកចម្រើនឡើងជារៀងរាល់ឆ្នាំដូចនេះហើយផលិតកម្មសត្វដើរតួយ៉ាងសំខាន់ ក្នុងការផ្គត់ផ្គង់ម្ហូបអាហារដែលផ្តល់នូវប្រូតេអ៊ីនខ្ពស់ និងជាប្រភពថវិកាមួយដ៏សំខាន់ ក្នុងការចូលរួមចំណែកលើកស្ទួយជីវភាពរស់នៅរបស់ប្រជាកសិករ ។ មិនតែប៉ុណ្ណោះ ការចិញ្ចឹមគោ ក្របី ក៏ជាផ្នែកមួយដ៏សំខាន់ក្នុងប្រព័ន្ធកសិកម្មសមស្របនៅប្រទេសកម្ពុជា។ ជាទូទៅកសិករចិញ្ចឹមសត្វ គោ ក្របី ជាលក្ខណៈគ្រួសារ ហើយត្រូវបានយកទៅប្រើប្រាស់ជាកម្លាំងអូសទាញ បើទោះជាមានគ្រឿងយន្តមកជំនួសក្តី។ ជាងនេះទៅទៀត គោ ក្របី ជាប្រភពចំណូលមួយដ៏សំខាន់ប្រចាំគ្រួសារ និងផ្តល់ជាម្ហូបអាហារចាំបាច់ទៀតផង។

បច្ចុប្បន្ននេះ ការចិញ្ចឹម គោ ក្របី របស់កសិករជួបប្រទះនូវបញ្ហាជាច្រើនដែលអាចរាំងស្ទះដល់ដំណើការផលិតកម្ម។ កត្តាជាច្រើនដែលជំរុញឱ្យការចិញ្ចឹមគោ-ក្របីអាចទទួលបានជោគជ័យ មានដូចជា៖ ការថែទាំ និងអនាម័យ ការជ្រើសរើសពូជ និងការបង្កាត់ពូជ ចំណីអាហារ និងវិធានការការពារជំងឺជាដើម ។

ការចិញ្ចឹមសត្វភាគច្រើនកំពុងជួបប្រទះលើបញ្ហាសុខភាព ដែលធ្វើឱ្យកសិករខាតបង់ពេលវេលា ការងារ ថវិកាទៀតផង។

ការកង្វះខាតចំណីអាហារគឺជាប្រពៃណីនៃការចិញ្ចឹមគោ-ក្របីរបស់កសិករទូទៅ។ បញ្ហាកំពុងជួបប្រទះ និងជាការលំបាកយ៉ាងខ្លាំង ភាគច្រើននៅរដូវប្រាំងដែលស្មៅធម្មជាតិក្រៀមស្វិត ដូចនេះគោក្របីទទួលបានតែចំណីដូចជា ចំបើង ឬគល់ជញ្ជ្រាំង ប៉ុណ្ណោះ បណ្តាលឱ្យសត្វមានសភាពស្គមស្គាំងស្លេកស្លាំង បាក់កម្លាំង ការបន្តពូជថយចុះ ងាយទទួលរងនូវជំងឺ និងអាចងាប់ជាដើម ។

ការដាំដំណាំចំណីសត្វមានសារៈសំខាន់ដល់កសិករ ដើម្បីបង្កើនបរិមាណ និង